**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ១១.០៤៨/០៧ គ.ជ.ប.អគ្គ.៣ស** ភ្នំពេញ ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧

# ក្រុមប្រឹក្សាជំនុំជំរះ គ.ជ.ប សម្រេចលុបឈ្មោះចំនួន ៣.៦៩៦ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូង

នៅថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ក្រុមប្រឹក្សាជំនុំជំរះ គ.ជ.ប បានបើកសវនាការជំនុំជំរះជាសាធារណៈ ហើយបានសម្រេចលុបឈ្មោះចំនួន **៣.៦៩៦** នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូងនៅឃុំ សង្កាត់ ចំនួន **៨** គឺនៅក្រុងភ្នំពេញ **១** សង្កាត់ ខេត្តកណ្ដាល **២** ឃុំ និងខេត្តព្រៃវែង **៥** ឃុំ ។

បណ្ដឹងដែលក្រុមប្រឹក្សាជំនុំជំរះ គ.ជ.ប លើកយកមកបើកសវនាការនេះ ជាបណ្ដឹងរបស់លោក លីន ញ៉ក់ និងលោក សន សោភ័ណ្ឌ តំណាងគណបក្សប្រជាជនកម្ពុជា បានប្ដឹងសុំលុបឈ្មោះ ចំនួន **៣.២៤៤** នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូងនៅសង្កាត់ គីឡូម៉ែតលេខ៦ ខ័ណ្ឌឬស្សីកែវ ក្រុងភ្នំពេញ ដោយសំអាងថា អ្នកទាំងនោះពុំមានទីលំនៅក្នុងសង្កាត់នេះ។ បណ្ដឹងនេះត្រូវបានក្រុមប្រឹក្សាសង្កាត់ គីឡូម៉ែតលេខ៦ ធ្វើការប្រជុំសម្រេចម្ដងរួចមកហើយ កាលពីថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ដោយរក្សាទុកឈ្មោះទាំងនោះនៅក្នុងបញ្ជីដំបូងដដែល ហើយបណ្ដឹងនេះត្រូវបានប្ដឹងតវ៉ាមក គ.ជ.ប បន្តទៀត ។ បន្ទាប់ពីបានសួរដេញដោលរួចមកក្រុមប្រឹក្សាជំនុំជំរះ បានសម្រេចលុបឈ្មោះចំនួន **៣.២៤៤** នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូង ហើយបដិសេធសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសង្កាត់ គីឡូម៉ែតលេខ៦ ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ចោលជាអាសារបង់ និងបើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។

ដោយឡែកបណ្ដឹងមួយទៀត គឺបណ្ដឹងរបស់លោក ពឹម សំណាង និងលោក ឡុង លីមហ៊ា តំណាងគណបក្សសម រង្ស៊ី ។ លោក ពឹម សំណាង បានប្ដឹងសុំលុបឈ្មោះចំនួន **៨៧៩** នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូងនៅឃុំ ចំនួន **៥** ក្នុងខេត្តព្រៃវែង គឺឃុំអ្នកលឿង ចំនួន **៨១** នាក់ ឃុំព្រែកខ្សាយ ខ ចំនួន **៣១៨** នាក់ ឃុំពាមរក៏ ចំនួន **២១៩** នាក់ ឃុំបាបោង ចំនួន **៧៧** នាក់ និងឃុំរាធរ ចំនួន **១៨៤** នាក់ ដោយសំអាងថា អ្នកទាំងនោះជាជនជាតិវៀតណាម ពុំមែនជាជនជាតិខ្មែរ ហើយព្រះមហាក្សត្រពុំទាន់បានឡាយព្រះហស្ថលេខានៅឡើយទេ ។ បន្ទាប់ពីសួរដេញដោលដើមបណ្ដឹង និងចុងចម្លើយរួចមក ក្រុមប្រឹក្សាជំនុំជំរះបានសម្រេច :

- លុបឈ្មោះចំនួន **៤៤** នាក់ និងរក្សាទុកចំនួន **២១** នាក់ ក្នុងបញ្ជីបោះឆ្នោតដំបូងនៅឃុំអ្នកលឿង ចំណែកចំនួន **១៦** នាក់ ទៀតត្រូវបានក្រុមប្រឹក្សាឃុំសម្រេចលុបរួចមកហើយ កាលពីថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៧។
- ឃុំព្រែកខ្សាយ ខ លុបឈ្មោះចំនួន **១៧២** នាក់ និងរក្សាទុកចំនួន **៩៨** នាក់ ហើយចំនួន **៤៨** នាក់ ត្រូវបានក្រុមប្រឹក្សាឃុំលុបរួចមកហើយ កាលពីថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ។
- ឃុំពាមរក៏ លុបឈ្មោះចំនួន **១២៧** នាក់ និងរក្សាទុកចំនួន **៩២** នាក់ ។
- ឃុំបាបោង លុបឈ្មោះចំនួន **៧៧** នាក់
- ឃុំរាធរ លុបឈ្មោះចំនួន **៣២** នាក់ និងរក្សាទុកចំនួន **១៥២** នាក់

ចំពោះ លោក ឡុង លីមហ៊ា បានប្ដឹងសុំលុបឈ្មោះចំនួន **២.០៣៣** នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូង នៅឃុំចំនួន ២ ក្នុងខេត្តកណ្ដាល គឺឃុំសំពៅពូន ចំនួន **៧០២** នាក់ និងឃុំព្រែកជ្រៃ ចំនួន **១.៣៣១** នាក់ ដោយសំអាងថា អ្នកទាំងនោះជាជនជាតិវៀតណាម គ្មានឯកសារគ្រប់គ្រាប់សម្រាប់ធ្វើការបោះឆ្នោត និងពុំមានទីលំនៅច្បាស់លាស់ ។ ហើយបណ្ដឹងនេះក្រុមប្រឹក្សាជំនុំជំរះ គ.ជ.ប បានសម្រេចរក្សាទុកឈ្មោះទាំងនោះក្នុងបញ្ជីបោះឆ្នោតដំបូង នៃឃុំទាំងពីរនេះដដែល ហើយបើកផ្លូវប្ដឹងតវ៉ាក្នុងអំឡុងពេលកំណត់ច្បាប់ ។